# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 620

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការជំរុញការងារស្តារព្រៃឈើនៅកម្ពុជានិងវៀតណាមតាមរយៈការបង្កើតឡូត៍បង្ហាញ និងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធចែកចាយគ្រាប់ពូជឈើ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/15 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/19 |
| ៣. ចំណាយគម្រោងសរុប | $500,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| RESPONSIBLE UNIT | Forestry Administration |
| អង្គភាពទទួលខុសត្រូវ | រដ្ឋបាលព្រៃឈើ |
| ៥. ស្ថានភាពគម្រោង | គម្រោងដែលបានបញ្ចប់ |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងជំនួយបច្ចេកទេស |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ជំនួយឥតសំណង |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

-ទីតាំងប្រភពគ្រាប់ពូជឈើក្នុងព្រៃធម្មជាតិត្រូវបានកំណត់

-សមត្ថភាពរបស់ រ.ពក្នុងវិស័យគ្រាប់ពូជឈើត្រូវបានបង្កើន

-ប្រព័ន្ធផ្គត់ផ្គង់ (ទីផ្សារ) គ្រាប់ពូជឈើត្រូវបានកែលម្អ

-បង្កើតឡូត៏បង្ហាញអំពីការស្តារព្រៃឈើ

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កំពង់ធំ, តាកែវ, កោះកុង, ព្រះសីហនុ, ពោធិ៍សាត់, ព្រះវិហារ, មណ្ឌលគិរី, កំពង់ស្ពឺ, កំពង់ឆ្នាំង, ឧត្តរមានជ័យ, ស្ទឹងត្រែង, រាជធានីភ្នំពេញ, សៀមរាប,

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

-ផ្តួចផ្តើមឲ្យមានប្រព័ន្ធចែកចាយគ្រាប់ពូជឈើនៅកម្ពុជា (កំណត់ទីតាំងប្រភពគ្រាប់ពូជឈើ និងអ្នកផ្គត់ផ្គង់ គ្រាប់ពូជឈើ
- បង្កើតឲ្យមានបន្ទប់ពិសោធន៍គ្រាប់ពូជឈើ និងពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើ
- បង្កើតឡូតិ៍បង្ហាញការស្តារព្រៃឈើនៅកម្ពុជា

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងការជំរុញការងារស្តារព្រៃឈើនៅកម្ពុជា និងវៀតណាម តាមរយៈការបង្កើតឡូត៍បង្ហាញ និងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធចែកចាយគ្រាប់ពូជឈើត្រូវបានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងសាធារណរដ្ឋកូរ៉េ និងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម នាថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤។ គម្រោងនេះស្ថិតក្រោមជំនួយឧបត្ថម្ភពីកម្មវិធី AFoCo (ASEAN-ROK Forest Cooperation) និងមានរយៈពេលអនុវត្ត ៥ឆ្នាំ ដោយគិតចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៩។ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ នៃរដ្ឋបាលព្រៃឈើជាអ្នកអនុវត្ត គម្រោងដោយសហការជាមួយនឹងរដ្ឋបាលព្រៃឈើនៃប្រទេសវៀតណាម។ នេះជាគម្រោងថ្នាក់តំបន់ដែលមានប្រទេសពីរចូលរួមអនុវត្តគឺប្រទេសកម្ពុជា និងប្រទេសវៀតណាម។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ជម្រុញការស្តារព្រៃឈើតាមរយៈការធ្វើឲ្យងាយស្រួលស្វែងរកគ្រាប់ពូជឈើ និងឡូត៍បង្ហាញស្តារព្រៃឈើ។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងការជំរុញការងារស្តារព្រៃឈើនៅកម្ពុជា និងវៀតណាម តាមរយៈការបង្កើតឡូត៍បង្ហាញ និងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធចែកចាយគ្រាប់ពូជឈើ នឹងរួមចំណែកយ៉ាងច្រើនសម្រាប់វិស័យព្រៃឈើជាពិសេសគឺចំពោះអ្នកដែលពាក់ព័ន្ធក្នុងកម្មវិធីស្តារព្រៃឈើ (កសិករ សហគមន៍ព្រៃឈើ អង្គការជាតិ និងអន្តរជាតិ ក្រុមហ៊ុនដាំឈើ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត)

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទាន់ចាប់ផ្តើម** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រតាមរយៈការបណ្តុះបណ្តាលដល់សហគមន៍មូលដ្ឋានលើជំនាញគ្រាប់ពូជឈើ (បង្កើតការងារ) ហើយប្រជាសហគមន៍មួយចំនួន នឹងក្លាយជាអ្នកផ្គត់ផ្គង់គ្រាប់ពូជឈើ។ ជំនាញថ្មី នឹងក្លាយជាប្រភពចំនូលបន្ថែមក្រៅពីប្រភពចំណូលប្រចាំថ្ងៃរបស់ពួកគាត់។

**១៩. ការប្រែប្រួល អាកាសធាតុ**

| | |
|---|---|
| ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? | **មាន** |
| ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស | **ការកាត់បន្ថយ** |

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
| --- | --- | --- |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការកាត់បន្ថយ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**ស្ត្រី និងបុរសត្រូវបានអញ្ជើញ ចូលរួមនៅក្នុងសកម្មភាពនានារបស់គម្រោងដូចជាកិច្ចប្រជុំពិគ្រោះ យោបល់សកម្មភាពនៅទីវាល (កសិរុក្ខកម្ម និងសហគ្រិនភាព)**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**មន្ត្រីទទួលអនុវត្តន៍គម្រោងមានជំនាញ និងបទពិសោធន៍គ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោងនេះ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

គម្រោងនេះបានបញ្ចប់នូវផែនការអនុវត្តសម្រាប់ឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣(២០១៥-២០១៧) បានយ៉ាងរលូន និងបានសម្រេចនូវផែនការសំខាន់ៗជាច្រើនដូចជា

ο ប្រភពគ្រាប់ពូជឈើនៅក្នុងដំណុះព្រៃធម្មជាតិចំនួន ១៥កន្លែង (និងអ្នកទំនាក់ទំនង) ត្រូវបានកំណត់ដោយរួមមានប្រភេទឈើអាទិភាពសម្រាប់ដាំដុះ និងអភិរក្សប្រមាណជា ២០ ប្រភេទ។ ភាគច្រើននៃប្រភពគ្រាប់ពូជឈើត្រូវបានកំណត់នៅក្នុងដែនព្រៃសហគមន៍ និងតំបន់ការពារ។

ο បានផលិតជាឯកសារផ្សព្វផ្សាយអំពីប្រភពគ្រាប់ពូជឈើ (Leaflet) សៀវភៅស្តីពី ប្រភពគ្រាប់ពូជឈើ និងឡូត៍បង្ហាញស្តារព្រៃឈើបង្កើតឡើងក្រោមជំនួយថវិកាពី AFoCO និងផ្ទាំងផ្សព្វផ្សាយអំពីសមិទ្ធិផលគម្រោង ព្រមទាំងបានចែកចាយដល់អ្នកពាក់ព័ន្ធនានាក្នុងការងារ ដាំឈើដែលធ្វើឲ្យអ្នកដាំឈើមានភាពងាយស្រួលជាងមុនក្នុងការស្វែងរកគ្រាប់ពូជឈើ និង បច្ចេកទេសដាំឈើ។

ο ចម្ការពូជឈើនៅក្នុងតំបន់ទីជម្រាលក្បាលឆាយប្រមាណជិត ១០ ហិកតា ត្រូវបានថែរក្សា។

ο បន្ទប់មួយនៅក្នុងអគារ វ.ស.អ. ត្រូវបានបំលែងទៅជាមន្ទីរពិសោធន៍គ្រាប់ពូជឈើ និងបានបំពាក់សម្ភារៈមួយចំនួនសម្រាប់ឲ្យមន្ទីរពិសោធន៍គ្រាប់ពូជឈើមានដំណើរការ ។

ο មន្ត្រី វ.ស.អ មួយរូប (អ្នកស្រី រិន ចិន្តា) បានទទួលការបណ្តុះបណ្តាលនៅសាធារណរដ្ឋកូរ៉េ លើមុខជំនាញ បច្ចេកវិជ្ជាគ្រាប់ពូជឈើ។ មន្ត្រី វ.ស.អ ៥ រូបទៀតបានទទួលការបណ្តុះបណ្តាលលើជំនាញគ្រាប់ពូជឈើនៅក្នុងប្រទេសតាមរយៈវគ្គបណ្តុះបណ្តាលខ្លីៗដែលរៀបចំដោយគម្រោង ។

ο បានដំណើរការមន្ទីរពិសោធន៍ជាលិកាវប្បកម្ម ដែលមានមន្ត្រីចូលរួមសរុបចំនួន៤នាក់

ο បានបង្កើតចម្ការឈើ ធាំធា តាត្រាវ ប្រេស អាកាស្យាស្លឹកតូច អាកាស្យាស្លឹកធំ ដែលចម្ការពូជឈើនីមួយៗមានទំហំ១ហិកតា (សរុប ៥ហិកតា) នៅក្នុងឃុំយុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលអនាគតនឹងក្លាយទៅជាតំបន់ផលិតគ្រាប់ពូជឈើ។

ο បានបង្កើតឡូត៍បង្ហាញស្តារព្រៃឈើដោយដាំឈើចម្រុះប្រភេទ (២៦ ប្រភេទ) ក្នុងកំរិតដង់ស៊ីតេខ្ពស់ទំហំ ២ ហិកតា និងឡូត៍បង្ហាញស្តារព្រៃឈើដោយដាំឈើដោយគ្រាប់ ទំហំ ១ហិកតា នៅក្នុងឃុំយុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

ο ថែរក្សាឡូត៍បង្ហាញស្តារព្រៃឈើ ដាំដោយគ្រាប់ ទំហំ២ហិកតា នៅក្នុងឃុំយុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

២៤. **អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

២៥. **ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះស្ថិតក្រោមជំនួយឧបត្ថម្ភពីកម្មវិធី AFoCO (ASEAN-ROK Forest Cooperation) និងមានរយៈពេលអនុវត្ត ៥ឆ្នាំ ដោយគិតចាប់ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៩។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2018 | | 2019 | 2020 | 2021 | 2022 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2020-2022 | ចរន្ត |
| ចំណាយប្រតិបត្តិ | 19.0 | 0.0 | 19.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 18.0 | 0.0 | 18.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 1.0 | 0.0 | 1.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ចំណាយមូលធន** | 84.5 | 0.0 | 59.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្ដុះបណ្ដាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 84.5 | 0.0 | 59.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 103.5 | 0.0 | 78.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2018 | | 2019 | 2020 | 2021 | 2022 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2020-2022 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 103.5 | 0.0 | 78.6 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Republic of Korea | 103.5 | 0.0 | 78.6 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 103.5 | 0.0 | 78.6 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

បានឃើញ និង ឯកភាព

រដ្ឋមន្ត្រី

កាលបរិច្ឆេទ: